# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៦ ស្តីពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ៧៧

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៧ ស្តីពីការតែងតាំងឯកឧត្តម **ចង់ សណ្ដាប់** ជាសមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៩២

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣០ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ៩៣

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣១ ស្តីពីការតែងតាំងមន្ត្រីតុលាការ ៩៤

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣២ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីតុលាការ ៩៥

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៣ ស្តីពីការដាក់វិន័យលោក **យ៉ារ៉ា យ៉េត** ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តបាត់ដំបង ក្រោមរូបភាពផ្លាស់ដោយបង្ខំចេញពីអយ្យការអមតុលាការខេត្តបាត់ដំបង ៩៨

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៤ ស្តីពីការតែងតាំងសិស្សចៅក្រមជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ៥៥ នាក់ ទៅបំរើការងារជាចៅក្រមកម្មសិក្សា និង ព្រះរាជអាជ្ញារងកម្មសិក្សា នៅតាមតុលាការខេត្ត-ក្រុង និងអង្គភាពមួយចំនួន ៩៩

៣០-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៥ស្តីពី :

-ការសំរួលភារកិច្ច ឯកឧត្តម **ស៊ិន សារុន** ដោយបញ្ចប់សមាជិកភាព ជាសមាជិកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

-តែងតាំង ឯកឧត្តម **ភាន់ ម៉ន** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ស៊ិន សារុន** ១០៣

៣០-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៦ ស្តីពីការតែងតាំងឯកឧត្តម **ឈួន សុធី** ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្ន ដែលជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ១០៥

៣០-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥៣៧ ស្តីពីការតែងតាំងឯកឧត្តម **សាត សាមី** ជាជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១០៦

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៥-០១-២០០៦ -អនុក្រឹត្យលេខ០១អនក្រ.បកស្តីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០០ រៀល គំរូថ្មី ១០៧

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្តីពីការប្តូរឈ្មោះមុខតំណែងមន្ត្រីរាជការ ១០៨

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៩

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១១០

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១១

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៧ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ១១២

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ១១៣

០៥-០១-២០០៦ -អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ១១៤

០៥-០១-២០០៦ -អនុក្រឹត្យលេខ ១០ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ១១៥

០៥-០១-២០០៦ -អនុក្រឹត្យលេខ ១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១៦

០៥-០១-២០០៦ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១៧

០៥-០១-២០០៦ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១៨

០៥-០១-២០០៦ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១៩

០៦-០១-២០០៦ -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១២០


## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៦-០១-២០០៦ -សារាចរណែនាំលេខ ០០២សហវ.ពដ ស្តីពីការអនុវត្តន៍ចុះបញ្ជីពន្ធដាររបស់សហគ្រិនវិនិយោគ ១២២

០៦-០១-២០០៦ -សេចក្តីជូនដំណឹងលេខ ០០១ សហវ ស្តីពីកាតព្វកិច្ចអាករលើតម្លៃបន្ថែម (VAT) ១២៤

០៦-០១-២០០៦ -សេចក្តីជូនដំណឹងលេខ ០០២ សហវ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ ១២៥

06-01-2006 - NOTICE Nº 002 MEF/. Date 06 January 2006 ១២៦


### ២. ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


០៤-០១-២០០៦ -ប្រកាសលេខ ០០៤ ឧរថ.កឧប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ភីស គ្គីរ (ខេមបូឌា) មេនូហ្វេកឈ័ររីង បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ភីស គ្គីរ (ខេមបូឌា) មេនូហ្វេកឈ័ររីង" ១២៧

## ៣-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម


០៣-០១-២០០៦ -លិខិតលេខ ០០៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស្មើ សួគ៌ ហ្វាម៉ា** ១២៩

០៣-០១-២០០៦ -លិខិតលេខ ០០៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូណាយធីត ថេកនីខល សឺវីស (យូធីអេស)** ១៣១

០៣-០១-២០០៦ -លិខិតលេខ ០១៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **បូយ៉ាង ខនស្ត្រាក់សិន អ៊ិនជីនារីង អ៊ិនធើប្រាយ** ១៣៣

០៣-០១-២០០៦ -លិខិតលេខ ០១៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ូឌែន ទីសិន គ្រុប** ១៣៥

០៣-០១-២០០៦ -លិខិតលេខ ០២០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ប៊ី & ខេ អ៊ិនធើប្រាយ** ១៣៧

០៣-០១-២០០៦ -លិខិតលេខ ០២៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ិនថាមុន្នី អ៊ិនវេសមេន គ្រុប " ប៊ី អាយ ជី "** ១៣៩

០៣-០១-២០០៦ -លិខិតលេខ ០២៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **មាស សត្យា គ្រុប** ១៤១

០៣-០១-២០០៦ -លិខិតលេខ ០២៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស សាន់រ៉ាយ** ១៤៣

០៣-០១-២០០៦ -លិខិតលេខ ០២៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គៀង សេង អ៊ីមផត អិចផត ខូ អិលធីឌី** ១៤៥

០៣-០១-២០០៦ -លិខិតលេខ ០២៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី ជេ ស៊ី ជី គ្រុប** ១៤៧

០៣-០១-២០០៦ -លិខិតលេខ ០២៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សម្បូរផល អ៊ីមផត អិចផត** ១៤៩

០៣-០១-២០០៦ -លិខិតលេខ ០៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហួរ សុខា ពាណិជ្ជ ខូ អិលធីឌី** ១៥១

០៣-០១-២០០៦ -លិខិតលេខ ០៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ពេទ្រូ ស** ១៥៣

០៣-០១-២០០៦ -លិខិតលេខ ០៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គោលដេន ជីនលីន អ៊ិនធើ
ប្រាយ ខូ អិលធីឌី** ១៥៥

០៣-០១-២០០៦ -លិខិតលេខ ០៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស្តារ អេស៊ា ត្រាំវែល & ធួរ** ១៥៧

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥២៦

## ស្តីពី

## សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

# ព្រះរាជក្រឹត្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

បង្កើតសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដែលមានវិសាលភាពទូទាំងប្រទេសកម្ពុជា ហើយដែលធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍ដល់មុខរបរ និងមីក្រូសហគ្រាសក្នុងគោលបំណងជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជួយបង្កើនធនធានមនុស្ស និងការបង្កើតអាជីពតាមរយៈមុខរបរ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា ។

សភាមុខរបរ និង មីក្រូសហគ្រាស នៅថ្នាក់ខេត្ត-ក្រុង នឹងត្រូវបង្កើតឡើង ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមសំណើរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ២ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺជានីតិបុគ្គលឯកជនមួយ ដែលចងក្រងបង្កើតឡើងដើម្បីបំពេញបេសកកម្ម ដែលមានលក្ខណៈបម្រើផលប្រយោជន៍សាធារណៈ។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺជាយន្តការបំពេញបន្ថែមឱ្យសភាពាណិជ្ជកម្មកម្ពុជា ។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ស្ថិតនៅក្រោមអាណាព្យាបាលជំនាញរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៣ .-**

សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺបណ្តាអាជីវករមុខរបរ និងមីក្រូសហគ្រាសដែលបានចុះឈ្មោះក្នុងបញ្ជីមុខរបរ នៅសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

នីតិវិធីនៃការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា ៤ .-**

អាជីវករមុខរបរ និងមីក្រូសហគ្រាស គឺជារូបវ័ន្តបុគ្គល ឬក្រុមគ្រួសារទាំងឡាយណា ដែលប្រកបអាជីវកម្មដូចមាន កំណត់ក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅទីកន្លែងជាប្រចាំណាមួយ សំដៅសម្រេចឱ្យបាននូវផលិតផលអ្វីមួយ។

អាជីវកម្មមុខរបរ និងមីក្រូសហគ្រាស ដែលមានលក្ខណៈគ្រួសារ គឺអាជីវកម្មដែលគ្មានប្រើប្រាស់កម្មករ ឬប្រើប្រាស់កម្មករ ដោយរាប់បញ្ចូលប្រពន្ធ និងកូន។

**មាត្រា ៥ .-**

បញ្ជីសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស គ្រប់គ្រងដោយសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។ អាជីវករមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យនេះ អាចអនុញ្ញាត និងទទួលចុះឈ្មោះក្នុងបញ្ជីសមាជិកភាពនេះបាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌចាំបាច់គឺរូបវ័ន្តបុគ្គល ឬគ្រួសារ ដែលអាចបញ្ជាក់អំពីសមត្ថភាព ឬ បទពិសោធន៍ យ៉ាងហោចណាស់ ៦ ខែ ។

សមាជិកភាពនេះ តម្រូវឱ្យបង់ភាគទានសមស្របទៅតាមការកំណត់ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងដោយឡែក និងទទួលសិទ្ធិប្រើប្រាស់សេនាសនភណ្ឌរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ៦ .-**

សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជាមានតំណាងរបស់ខ្លួន ដែលជ្រើសតាំងតាមរយៈការបោះឆ្នោតនៃមហាសន្និបាត។ ចំនួនអ្នកតំណាងនៃសមាជិកមុខរបរ និងមីក្រូសហគ្រាស នៅក្នុងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់មហាសន្និបាត ហើយត្រូវបានបែងចែកតាមចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ដូចខាងក្រោម ÷

ក- អាជីវកម្មផលិតចំណីអាហារ

ខ- អាជីវកម្មប្រតិស្ឋកម្ម

គ- អាជីវកម្មសំណង់

ឃ- អាជីវកម្មសេវាកម្ម

ង- មុខរបរ និងមីក្រូសហគ្រាសផ្សេងៗទៀត ស្របតាមមាត្រា៧នៃព្រះរាជក្រឹត្យនេះ ។

ចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាសនីមួយៗ កំណត់នៅក្នុងឧបសម្ព័ន្ធភ្ជាប់។

តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស គឺជាសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដែលត្រូវបានជ្រើសតាំងដោយមហាសន្និបាតតំណាងទូទាំងប្រទេស។

**មាត្រា ៧ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិអំណាចពង្រីកបន្ថែមនូវអាជីវកម្មមុខរបរ និងមីក្រូសហគ្រាស ដែល កំណត់ពីសកម្មភាពនានា សម្រាប់រាប់បញ្ចូលក្នុងចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាស។ មុខរបរ និងមីក្រូសហគ្រាស ជាប្រពៃណីជាតិ ទទួលបានការលើកទឹកចិត្តជាអាទិភាព។

**មាត្រា ៨ .-**

អាជីវករមុខរបរ និងមីក្រូសហគ្រាស ដែលមានមុខរបរដូចគ្នា ឬក៏មានមុខជំនាញប្រហាក់ប្រហែលគ្នា អាចរួមគ្នាបង្កើតជាសមាគមជំនាញមុខរបរ និង មីក្រូសហគ្រាស នៅថ្នាក់មូលដ្ឋានបាន តាមការណែនាំពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ៩ .-**

ការបង្កើតសមាគមជំនាញមុខរបរ និងមីក្រូសហគ្រាសនេះ ធ្វើឡើងក្នុងគោលបំណងលើកស្ទួយផលប្រយោជន៍រួម របស់សមាជិកខ្លួន។ សមាគមនេះមានភារកិច្ចសំខាន់ៗ ដូចតទៅ ÷

- ថែរក្សាប្រពៃណីអាជីវកម្ម
- បង្កើនការទាក់ទងល្អរវាងម្ចាស់អាជីកម្មមុខរបរ និងមីក្រូសហគ្រាស និងសហការីរបស់ខ្លួន
- ជួយដល់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្នុងការសម្របសម្រួលដំណើរការបណ្តុះបណ្តាលលើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអភិវឌ្ឍន៍ទេពកោសល្យជំនាញ
- ជួយសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ជំពូកទី ២

## តួនាទី និងភារកិច្ច របស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

**មាត្រា ១០ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានភារកិច្ចដូចតទៅ ÷

- ជំរុញ និងណែនាំអំពីរបៀបបង្កើតសមាគមជំនាញមុខរបរ និងមីក្រូសហគ្រាស
- ទ្រទ្រង់ផលប្រយោជន៍មុខរបរ និងមីក្រូសហគ្រាស និងបង្កើតយន្តការសមស្របមួយ ដើម្បីជួយគ្នាទៅវិញទៅមករវាងសមាជិកមុខរបរ និងមីក្រូសហគ្រាសនីមួយៗ
- សម្របសម្រួលភាពមិនចុះសម្រុងក្នុងមុខរបរ និងមីក្រូសហគ្រាស រវាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និង សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ឬរវាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និង អាជីវករទូទៅ
- ពិគ្រោះជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ចំពោះការប្រតិបត្តិឱ្យមានប្រសិទ្ធភាពនៃនយោបាយសេដ្ឋកិច្ចរបស់ខ្លួន

- គ្រប់គ្រងបញ្ជីសមាជិកមុខរបរ និងមីក្រូសហគ្រាស
- សម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការសុំលិខិតបញ្ជាក់ ឬទទួលស្គាល់គុណភាពស្តង់ដារផលិតផល ឬសេវាកម្មផ្សេងៗ របស់សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
- ចេញសេចក្តីណែនាំដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្របសម្រួលការបណ្តុះបណ្តាល ឬចេញវិញ្ញាបនប័ត្រដល់សិក្ខាកាម
- រៀបចំ និងលើកសំណើស្តង់ដារបច្ចេកទេស បរិស្ថាន និងសុវត្ថិភាពការងារ ដែលទាក់ទិននឹងជំនាញមុខរបរ និងមីក្រូសហគ្រាស ជូនអាជ្ញាធរមានសមត្ថកិច្ច
- ពិនិត្យលទ្ធភាពក្នុងការពង្រីកសកម្មភាពរបស់ខ្លួន ក្នុងគោលបំណងបម្រើផលប្រយោជន៍ ដូចដែលមានចែងក្នុងមាត្រា ១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរីកចម្រើន ក្នុងវិស័យមុខរបរ និងមីក្រូសហគ្រាស។

**មាត្រា ១១ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងទិសដៅ ÷

- ជួយណែនាំអាជីវករចូលជាសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
- ជួយសម្របសម្រួលវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ
- ជួយកំណត់លក្ខណៈសម្គាល់របស់ផលិតផល បច្ចេកវិជ្ជា ធានានូវសុវត្ថិភាពការងារ ជូនដល់អាជីវករ និងកម្មករ និងជួយរួមចំណែកក្នុងកិច្ចការពារបរិស្ថាន។

**មាត្រា ១២ .-**

រៀងរាល់ឆ្នាំ នៅដំណាច់ខែមីនា សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវបញ្ជូនរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងផ្សព្វផ្សាយ។

## ជំពូកទី ៣
## ការបណ្តុះបណ្តាល

**មាត្រា ១៣ .-**

អាជីវករ និងកម្មករនៃមុខរបរ និងមីក្រូសហគ្រាស ដែលបានចុះបញ្ជីហើយ អាចទទួលបាននូវការសម្របសម្រួល ក្នុងការបណ្តុះបណ្តាលពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ១៤ .-**

ការបណ្តុះបណ្តាលវិជ្ជាជីវៈ គោលដៅផ្តល់ដល់សិក្ខាកាមនូវចំណេះដឹង ចំណេះធ្វើ និងជំនាញចាំបាច់សម្រាប់កិច្ចដំណើរការសកម្មភាពមុខរបរ និងមីក្រូសហគ្រាស។ ចំណេះដឹង ចំណេះធ្វើ និងជំនាញ សម្រាប់សកម្មភាពមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ប្រព្រឹត្តទៅក្រោមកិច្ចសហការជាមួយក្រសួងមានសមត្ថកិច្ចជាជំហានៗ តាមរយៈគម្រោងផែនការបំពាក់បំប៉ន។

**មាត្រា ១៥ .-**

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើឡើងដោយផ្អែកលើកិច្ចព្រមព្រៀងមួយស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈ រវាងអាជីវករមុខរបរ និងមីក្រូសហគ្រាសដែលបើកការបណ្តុះបណ្តាល និងសិក្ខាកាម ឬតំណាងស្របច្បាប់របស់គេ។

**មាត្រា ១៦ .-**

ផ្អែកតាមសេចក្តីសម្រេចរបស់មហាសន្និបាត សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិរៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈបន្ត។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិយកថ្លៃពីសិក្ខាកាម ដែលតម្លៃនេះនឹងកំណត់ដោយសន្និបាតពេញអង្គ សម្រាប់ផែនការនៃការសិក្សាបន្តខាងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាថ្មី។

## ជំពូកទី ៤
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា ១៧ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

- មហាសន្និបាត
- សន្និបាតពេញអង្គ
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការឯកទេស
- លេខាធិការដ្ឋាន។

## ជំពូកទី ៥
## មហាសន្និបាត

**មាត្រា ១៨ .-**

មហាសន្និបាត គឺជាសម័យប្រជុំរបស់សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។ តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជានីមួយៗ ត្រូវបានជ្រើសរើសដោយមហាសន្និបាត ដែលមានអាណត្តិ ៥ ឆ្នាំ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាសន្និបាត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៩ .-**

តាមសំណើរបស់ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចេញប្រកាសទទួលស្គាល់តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស ដែលមហាសន្និបាតបានជ្រើសតាំង។

**មាត្រា ២០ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចេញប្រកាសទទួលស្គាល់ទីប្រឹក្សារបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា តាមសំណើរបស់ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

## ជំពូកទី ៦
## សន្និបាតពេញអង្គ

**មាត្រា ២១ .-**

ការប្រជុំរបស់តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ហៅថា "សន្និបាតពេញអង្គ ដែលជាអង្គសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា"។ សន្និបាតពេញអង្គ អនុម័តលើសេចក្តីសម្រេចទាំងឡាយ ក្នុងទិសដៅបម្រើ និងការពារ ផលប្រយោជន៍អាជីវករមុខរបរ និងមីក្រូសហគ្រាស ហើយសន្និបាតពេញអង្គនេះអាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពី សមាជិកជំនួន ២ ភាគ ៣ យ៉ាងតិច។

សន្និបាតពេញអង្គ ជ្រើសរើសបន្ថែមនូវអ្នកជំនាញ ៥ រូប យ៉ាងច្រើន ដែលមានវិជ្ជាជីវៈមុខរបរ និងមីក្រូសហគ្រាស តាមចង្កោមអាជីវកម្មនីមួយៗ ជាទីប្រឹក្សា។

**មាត្រា ២២ .-**

សន្និបាតពេញអង្គរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល ដែល មានអាណត្តិ ៥ ឆ្នាំ ។

តាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល សន្និបាតពេញអង្គ បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការឯកទេស ។ គណៈកម្មាធិការឯកទេសនីមួយៗ មានសមាជិកយ៉ាងតិច ៣ នាក់ ។

**មាត្រា ២៣ .-**

សន្និបាតពេញអង្គ សម្រេចការងារដូចខាងក្រោម ÷

១. បោះឆ្នោតជ្រើសតាំងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

២. បោះឆ្នោតជ្រើសតាំងសមាសភាពរបស់គណៈកម្មាធិការឯកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល

៣. អនុម័តគម្រោងថវិកាប្រចាំឆ្នាំ

៤. ផ្តល់សេចក្តីយល់ព្រមលើការទទួលឥណទាន និងជំនួយផ្សេងៗ

៥. ទិញ លក់ ដីធ្លី និងអាគារ

៦. កំណត់នូវភាគទាន សម្រាប់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និងការយកកម្រៃផ្សេងៗ

៧. ពិនិត្យ និងទទួលយល់ព្រមនូវគណនេយ្យប្រចាំឆ្នាំ

៨. ចេញសេចក្តីណែនាំជាគោលការណ៍ដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ

៩. ធ្វើសេចក្តីសម្រេចលើតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល

១០. ធ្វើវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុងរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ។

**មាត្រា ២៤ .-**

សន្និបាតពេញអង្គ ធ្វើឡើងជាសាមញ្ញ ២ ដងក្នុងមួយឆ្នាំ ។ សន្និបាតពេញអង្គវិសាមញ្ញ អាចធ្វើទៅតាមការចាំបាច់ ។ ប្រធានក្រុមប្រឹក្សាភិបាល កោះអញ្ជើញសន្និបាតពេញអង្គនេះជាលាយលក្ខណ៍អក្សរ ក្នុងកំឡុងពេល ២ សប្តាហ៍ មុនពេលបើកសន្និបាត ។ ក្នុងករណីបន្ទាន់ កំឡុងពេលនៃការកោះអញ្ជើញនេះត្រូវបង្រួញមកត្រឹម ៣ ថ្ងៃ ។

របៀបវារៈនៃសន្និបាតពេញអង្គ ត្រូវបានកំណត់នៅក្នុងកម្មវត្ថុនៃសន្និបាតពេញអង្គ ។ ក្នុងករណីចាំបាច់ដែលត្រូវលើកយករបៀបវារៈផ្សេងទៀតមកបន្ថែម ត្រូវមានការយល់ព្រមពីសមាជិកវត្តមាន ២ ភាគ ៣ ។

ការសម្រេចណាមួយក្នុងសន្និបាតពេញអង្គ ចាំបាច់ត្រូវកំណត់ជាកម្មវត្ថុ ឬរបៀបវារៈ ក្នុងសេចក្តីកោះអញ្ជើញ លើកលែងតែកម្មវត្ថុ ឬរបៀបវារៈណាត្រូវបានទទួលការយល់ព្រមពីសមាជិកវត្តមាន ២ ភាគ ៣ ឱ្យដាក់បញ្ចូលបន្ថែមលើរបៀបវារៈក្នុងសន្និបាតពេញអង្គ ។

នីតិវិធីក្រៅពីនេះ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៧
## ក្រុមប្រឹក្សាភិបាល

**មាត្រា ២៥ .-**

ដំណើរការសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល មានប្រធានមួយរូប អនុប្រធានមួយ ឬច្រើនរូប ហិរញ្ញិក អគ្គលេខាធិការ និងសមាជិក ៦ នាក់ ផ្សេងទៀត។

ប្រធាន អនុប្រធាន ហិរញ្ញិក និងអគ្គលេខាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ដោយមតិគាំទ្រភាគច្រើននៃសន្និបាតពេញអង្គ។

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

ក្រុមប្រឹក្សាភិបាល មានសិទ្ធិជ្រើសរើសទីប្រឹក្សាមួយរូប ឬច្រើនរូប។ អាណត្តិរបស់ទីប្រឹក្សា ស្មើនឹងអាណត្តិរបស់ក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសនាយកប្រតិបត្តិ និងនាយករង ដើម្បីដឹកនាំការងារប្រចាំថ្ងៃ។

ចំពោះមុខនេះ ប្រគល់ភារកិច្ចជូនសម្ព័ន្ធសិប្បកម្មកម្ពុជា ឱ្យទទួលបន្ទុកការងារបណ្ដោះអាសន្នជាលេខាធិការដ្ឋាននៃសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

ក្រុមប្រឹក្សាភិបាល ទទួលបន្ទុករៀបចំមហាសន្និបាតនៅដើមអាណត្តិថ្មី និងសន្និបាតពេញអង្គ ហើយនិងអនុវត្តសេចក្ដីសម្រេចរបស់មហាសន្និបាត និងសន្និបាតពេញអង្គ។

**មាត្រា ២៦ .-**

ប្រធានក្រុមប្រឹក្សាភិបាល មានភារៈដឹកនាំកិច្ចប្រជុំរបស់មហាសន្និបាត និងសន្និបាតពេញអង្គ។

ករណីប្រធានមានធុរៈ អនុប្រធានតាមឋានានុក្រមដឹកនាំកិច្ចប្រជុំ។

ប្រធានក្រុមប្រឹក្សាភិបាល ជូនដំណឹង ស្ដីពីកាលបរិច្ឆេទនៃមហាសន្និបាត និងសន្និបាតពេញអង្គ។

តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៨
## គណៈកម្មាធិការឯកទេស

**មាត្រា ២៧ .-**

គណៈកម្មាធិការឯកទេសរួមមាន :

- គណៈកម្មាធិការសវនកម្ម

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង
- គណៈកម្មាធិការចំពោះកិច្ច ។

**មាត្រា ២៨ .-**

គណៈកម្មាធិការសវនកម្ម ទទួលបន្ទុកត្រួតពិនិត្យលើការដឹកនាំ និងគណនេយ្យភាពរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជាទាំងមូល ។

**មាត្រា ២៩ .-**

គណៈកម្មាធិការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ទទួលបន្ទុកកិច្ចការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ហើយរៀបចំបញ្ចូលនូវប្រព័ន្ធបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមផ្នែកនីមួយៗ ក្នុងកម្មវិធីបណ្ដុះបណ្ដាលជាតិ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរ ទទួលបាននូវចំណេះដឹង និងស្ទាត់ជំនាញក្នុងសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៣០ .-**

គណៈកម្មាធិការចំពោះកិច្ច ត្រូវបានចាត់តាំងឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីអនុវត្តការងារដែលមានរយៈពេលខ្លី ។

## ជំពូកទី ៩
## លេខាធិការដ្ឋាន

**មាត្រា ៣១ .-**

លេខាធិការដ្ឋាន ដឹកនាំដោយនាយកប្រតិបត្តិមួយរូប និងនាយករងមួយ ឬច្រើនរូប ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល ទំនាក់ទំនង និងហិរញ្ញវត្ថុ ប្រចាំថ្ងៃ ។

**មាត្រា ៣២ .-**

លេខាធិការ មានតួនាទីដូចតទៅ ៖

- ទទួលបន្ទុកលើការរៀបចំបង្កើតសមាគម អាជីវកម្មមុខរបរ និងមីក្រូសហគ្រាស
- ទទួលបន្ទុកលើការផ្សព្វផ្សាយ រកទីផ្សារ និងបណ្ដុះបណ្ដាលមូលដ្ឋានគ្រឹះរយៈពេលខ្លី
- ទទួលបន្ទុកលើការរៀបចំ និងផ្ដល់បច្ចេកវិជ្ជាមុខរបរ និងមីក្រូសហគ្រាស
- ទទួលបន្ទុករាល់ការចេញវិញ្ញាបនប័ត្រដល់សិក្ខាកាម ដែលបានទទួលការបណ្ដុះបណ្ដាល

- ទទួលបន្ទុកសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលយកវិញ្ញាបនប័ត្រសម្រាប់ការនាំចេញផលិតផល
- ទទួលបន្ទុករាល់ការរៀបចំ និងលើកសំណើស្តង់ដារបច្ចេកទេស បរិស្ថាន និងសុវត្ថិភាពការងារ ដែលទាក់ទិននឹងជំនាញមុខរបរ និងមីក្រូសហគ្រាស ជូនអាជ្ញាធរមានសមត្ថកិច្ច
- ទទួលបន្ទុកលើការអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកលើការទាក់ទងជាមួយនឹងស្ថាប័នសាធារណៈ
- ទទួលបន្ទុកលើការសម្របសម្រួលគម្រោង
- ទទួលបន្ទុកលើការទាក់ទងជាមួយកម្មវិធីជាដៃគូ
- ទទួលបន្ទុកលើការរៀបចំ និងដឹកនាំកិច្ចប្រជុំរបស់បុគ្គលិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

ទទួលបន្ទុកលើការអនុវត្តការងារផ្សេងៗទៀត ដែលក្រុមប្រឹក្សាភិបាលប្រគល់ជូន ។

## ជំពូកទី ១០

## ហិរញ្ញប្បទាន

**មាត្រា ៣៣ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ប្រមូលភាគទានប្រចាំខែរបស់សមាជិក ក្នុងកម្រិតសមស្របមួយតាមសេចក្តីសម្រេចរបស់សន្និបាតពេញអង្គ។ សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិប្រើប្រាស់ និងចាត់ចែងប្រាក់ភាគទាន សម្រាប់ការចំណាយទៅលើដំណើរការទូទៅ ។

**មាត្រា ៣៤ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានថវិកា ២ ប្រភេទ។

ថវិកាប្រភេទ ១ ជាថវិកាដែលប្រើប្រាស់សម្រាប់ការប្រព្រឹត្តទៅរបស់ខ្លួន ។ ប្រភពចំណូលនៃថវិកានេះបានមកពី :

- ភាគទាន និងវិភាជន៍ប្រចាំឆ្នាំរបស់សមាជិក
- ចំណូល និងវិភាគទានមកពីប្រភពផ្សេងៗ
- កម្ចីឥណទានពីធនាគារ និងស្ថាប័នដទៃទៀត

ថវិកាប្រភេទ ២ ជាថវិកាគម្រោងការងារសហប្រតិបត្តិការ ដែលរៀបចំឡើងសម្រាប់មុខរបរ និងមីក្រូសហគ្រាសទាំងឡាយ ដែលខ្លួនគ្រប់គ្រង ។ ប្រភពថវិកានេះ បានមកពីប្រទេស និងស្ថាប័នផ្តល់ជំនួយ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣៦ .-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣៧ .-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ៥ ឆ្នាំ ២០០៥

នស.០៥១២.៥៦៥ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៤៨៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ៥ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

3/16

# ឧបសម្ព័ន្ធ

## នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៥/៥២៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសភាមុខរបរ និង មីក្រូសហគ្រាសកម្ពុជា

ចង្កោមមុខរបរ និងមីក្រូសហគ្រាសដែលជាសមាជិកនៅក្នុងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជារួមមានៈ

### ក) មុខរបរ និងមីក្រូសហគ្រាសម្ហូបអាហារ

១. អ្នកដុតនំប៉័ង និងអ្នកធ្វើបង្អែមដំណាប់
២. អ្នកបិតស្រា-កែឆ្នៃស្រា
៣. អ្នកផលិតទឹកផ្លែឈើ
៤. អ្នកធ្វើនំ និងស្ករគ្រាប់
៥. អ្នកកាប់សត្វ និងអ្នកលក់សាច់
៦. អ្នកផលិតផ្កាំជក់-ពារី
៧. កិនស្រូវ និង គ្រាប់ធញ្ញជាតិ
៨. ផ្លែឈើ និង បន្លែ
៩. ស្ករ ស្ករស
១០. ស្រា និងភេសជ្ជៈ

### ខ) មុខរបរ និងមីក្រូសហគ្រាសប្រតិស្នកម្ម

១. ជាងតុ ទូ
២. ជាងឈើធ្វើទ្វារបង្អួច
៣. ជាងធ្វើទូក និងកាណូត
៤. ជាងក្រឡឹង និងឈូសឈើ
៥. អ្នកក្រងផ្កៅ
៦. ធ្វើខ្សែ ខ្សែពួរ
៧. ជាងថ្មៃត្បូង
៨. អ្នកបោះពុម្ព
៩. ស្មូនកុលាលភាជន៍ (អ្នកធ្វើក្អម ចាន ឆ្នាំងដី)

១០. អ្នកតម្លើងគ្រឿងភ្លេង

១១. ជាងវៃនតា

១២. អ្នកត្បាញ-រវៃ អ្នកធ្វើព្រំ

១៣. សម្ងាប់ស្បែក និងផលិតផលអំពីស្បែក

១៤. ជាងចម្លាក់ និងជាងសូនរូប

១៥. ជាងមាស

១៦. ជាងប្រាក់ និងស្ពាន់ (ជាងទង)

១៧. ផលិតផលពីឈើ និងគ្រឿងសង្ហារឹម

១៨. អារឈើ ឈូសឈើ

១៩. បោះពុម្ព និងធ្វើសៀវភៅ

២០. ឧបករណ៍កីឡា

គ) មុខរបរ និងមីក្រូសហគ្រាសសំណង់

១. អ្នករៀបឥដ្ឋ

២. អ្នកដាក់ទ្វារបង្អួច

៣. អ្នកសង់ផ្លូវថ្នល់

៤. អ្នកជីកអណ្តូង

៥. អ្នកយករ៉ែខ្សាច់-គ្រួស និងថ្ម

៦. អ្នកលាបជញ្ជាំង

៧. អ្នកសំណង់លោហៈ

៨. ជាងសំណង់ម៉ាស៊ីន

៩. ជាងផ្សារដែក

១០. ផលិតផលពីដីឥដ្ឋ

១១. ផលិតផលកញ្ចក់ និង

ឃ) មុខរបរ និងមីក្រូសហគ្រាសសេវាកម្ម

១. ជាងកាត់ខោអាវប្រុស-អាវស្រី

២. ជាងស្បែកជើង

៣. ជាងធ្វើកាបូប

៤. ជាងកាត់សក់ស្ត្រី-ប្រុស

៥. អ្នកបោកអ៊ុត

៦. អ្នកថតរូប

៧. ជាងម៉ាស៊ីនត្រជាក់

៨. ជាងការ៉េ

៩. ជាងតទឹក

១០. ជាងភ្លើង

១១. ជាងវិទ្យុ និងទូរទស្សន៍

១២. ជាងនាឡិកា

១៣. ជាងឡាន

១៤. ជាងម៉ូតូ

១៥. អ្នកលាបថ្នាំ

ង) មុខរបរ និងមុខរបរផ្សេងៗទៀត ស្របតាមមាត្រា៧នៃព្រះរាជក្រឹត្យនេះ ។

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥២៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម វង់ សណ្តាប់ ជាសមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រ.ល-០៥១២-៥៦៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥* លេខ ៤៩១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

នស/រកត/១២០៥/៥៣០

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម:

១- លោកវរសេនីយ៍ឯក ខេង លីដា អត្តលេខ ០៧៣៤

២- លោកវរសេនីយ៍ឯក ម៉ន់ ជីតូ អត្តលេខ ០៧៧១

៣- លោកវរសេនីយ៍ឯក ញាណ ទិបុល អត្តលេខ ៥៤២២៦ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ០៩១៧. ៥៦៩

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥*

លេខ : ៤៩៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំង :

១-លោក **ខៀវ សាម៉េត** ចៅក្រមនិងជាអគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ ជាប្រធានតុលាការខេត្តកណ្តាល ។

២-លោក **អាំង មាលតី** អនុប្រធានតុលាការខេត្តសៀមរាប ជាប្រធានតុលាការខេត្តសៀមរាប ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥១២.៥៧០

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ០៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា១ : ត្រូវបានផ្ទេរភារកិច្ច :**

១-លោក ទិត សុទ្ធី ប្រធានតុលាការខេត្តកំពង់ចាម អោយទៅបំរើការងារជាប្រធានតុលាការខេត្តតាកែវ ។

២-លោក ហ្វួន ម៉ានី ប្រធានតុលាការក្រុងព្រះសីហនុ អោយទៅបំរើការងារជាប្រធានតុលាការខេត្តកំពត ។

៣-លោក ម្លច់ ឆ្លាម ប្រធានតុលាការខេត្តសៀមរាប អោយទៅបំរើការងារជាប្រធានតុលាការខេត្តកំពង់ចាម ។

៤-លោក **ម៉ុល ធន** ប្រធានតុលាការខេត្តកំពង់ស្ពឺ អោយទៅបំរើការងារជាប្រធានតុលាការខេត្តពោធិសាត់ ។

៥-លោក **តាំ ឈាន** ប្រធានតុលាការខេត្តតាកែវ អោយទៅបំរើការងារជាប្រធានតុលាការខេត្តស្វាយរៀង ។

៦-លោក **អ៊ុំ សារុន** ប្រធានតុលាការខេត្តកំពង់ឆ្នាំង អោយទៅបំរើការងារជាប្រធានតុលាការខេត្តកោះកុង ។

៧-លោក **ជា នល់** ប្រធានតុលាការខេត្តពោធិសាត់ អោយទៅបំរើការងារជាប្រធានតុលាការខេត្តព្រៃវែង ។

៨-លោកស្រី **ស្វាយ ស៊ីសារុត** ប្រធានតុលាការខេត្តព្រៃវែង អោយទៅបំរើការងារជាប្រធានតុលាការក្រុងព្រះសីហនុ ។

៩-លោក **ម៉ែន សារិត** ប្រធានតុលាការខេត្តស្វាយរៀង អោយទៅបំរើការងារជាប្រធានតុលាការខេត្តកំពង់ស្ពឺ ។

១០-លោក **ស៊ុន សួច** ប្រធានតុលាការខេត្តកោះកុង អោយទៅបំរើការងារជាប្រធានតុលាការខេត្តកំពង់ឆ្នាំង ។

១១-លោក **ខ្លូត ពេជ្រ** អនុប្រធានតុលាការខេត្តកណ្តាល អោយទៅបំរើការងារជាអនុប្រធានតុលាការខេត្តកំពង់ធំ ។

១២-លោកស្រី **ស៊ឹម សារ៉េម** អនុប្រធានតុលាការខេត្តកំពង់ធំ អោយទៅបំរើការងារជាអនុប្រធានតុលាការខេត្តកណ្តាល ។

១៣-លោក **ថោង អុល** ចៅក្រមតុលាការក្រុងភ្នំពេញ អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តកំពង់ចាម ។

១៤-លោក **យ៉ា សុខន** ចៅក្រមតុលាការក្រុងភ្នំពេញ អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តបន្ទាយមានជ័យ ។

១៥-លោក **ខៀវ សន** ចៅក្រមតុលាការខេត្តកំពង់ចាម អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តបាត់ដំបង ។

១៦-លោក **ឆាយ គង់** ចៅក្រមតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។

១៧-លោក និត្យ ឫទ្ធី ចៅក្រមតុលាការខេត្តបន្ទាយមានជ័យ អោយទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។

១៨-លោក ពេញ ទិបុល ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តក្រចេះ អោយទៅបំរើការងារជាព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកំពង់ចាម ។

១៩-លោក អ៊ុក ឆុច ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកំពង់ចាម អោយទៅបំរើការងារជាព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តក្រចេះ ។

២០-លោក យ៉េត ចរិយា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងភ្នំពេញ អោយទៅបំរើការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ ។

២១-លោក គ្រី សុខអ៊ី ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកណ្តាល អោយទៅបំរើការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងភ្នំពេញ ។

២២-លោក យូ ម៉ុនឆេង ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ អោយទៅបំរើការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបាត់ដំបង ។

២៣-លោក នាក់ ទឡ្សនា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពត អោយទៅបំរើការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកណ្តាល ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥១២.៥៧១

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥ លេខ: ០៨ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែម.ក ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានដាក់វិន័យលោក យុាំ យ៉េត ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តបាត់ដំបង ក្រោមរូបភាពផ្លាស់ដោយបង្ខំចេញពីអយ្យការអមតុលាការខេត្តបាត់ដំបង ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ទរល.០៥១៧.៥៣៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ០៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកម/០១០៥/០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើត រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងសិស្សចៅក្រមជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ៩៥ នាក់ ទៅបំរើការងារជាចៅក្រមកម្មសិក្សា និង ព្រះរាជអាជ្ញារងកម្មសិក្សា នៅតាមតុលាការខេត្ត-ក្រុង និងអង្គភាពមួយចំនួនដូចខាងក្រោម :

ក-លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់ការជំនុំជំរះរឿងក្តី មេដឹកនាំខ្មែរក្រហម

១-លោក **លឹម សុគន្ធា** ជាចៅក្រម

២-លោក **សេង ម៉ុនឃាង** ជាព្រះរាជអាជ្ញារង

ខ-តុលាការ-អយ្យការក្រុងភ្នំពេញ

១-លោកស្រី **ចាំង ស៊ីណាត** ជាចៅក្រម

២-លោក **គួ ពៅស៊ីន** ជាចៅក្រម

| | |
|---|---|
| ៣-លោក ម្លូង សុផល | ជាព្រះរាជអាជ្ញារង |

គ-តុលាការ-អយ្យការខេត្តកណ្តាល

| | |
|---|---|
| ១-លោកស្រី សែម សក្តិតូឡា | ជាចៅក្រម |
| ២-លោក យុន លាងម៉េង | ជាចៅក្រម |
| ៣-លោក អ៊ិត សុធា | ជាចៅក្រម |
| ៤-លោក យូ ម៉ុនណា | ជាចៅក្រម |
| ៥-លោក សោ ចណ្ណី | ជាចៅក្រម |
| ៦-លោក ច្រឹង ខ្មៅ | ជាព្រះរាជអាជ្ញារង |
| ៧-លោកស្រី ចានស្វ រស្មី | ជាព្រះរាជអាជ្ញារង |
| ៨-លោក កើត ចណ្ណារ៉េត | ជាព្រះរាជអាជ្ញារង |
| ៩-លោក គី ម៉ុណ្ណារ៉ា | ជាព្រះរាជអាជ្ញារង |

ឃ-តុលាការខេត្តកំពង់ស្ពឺ

| | |
|---|---|
| ១-លោកស្រី ស៊ី ចណ្ណនី | ជាចៅក្រម |
| ២-លោកស្រី ខៀវ សុខា | ជាចៅក្រម |

ង-តុលាការ-អយ្យការខេត្តតាកែវ

| | |
|---|---|
| ១-លោក ហុក ម៉ាន់ធីណា | ជាចៅក្រម |
| ២-លោក យស់ ណារ៉ុង | ជាចៅក្រម |
| ៣-លោក មាស ចំនួពិសិដ្ឋ | ជាព្រះរាជអាជ្ញារង |
| ៤-លោក ចំនួ រង្សី | ជាព្រះរាជអាជ្ញារង |

ច-តុលាការ-អយ្យការខេត្តកំពត

| | |
|---|---|
| ១-លោក សេង នាង | ជាចៅក្រម |
| ២-លោក លឹម មករវន្ត | ជាចៅក្រម |
| ៣-លោក អៀង សៀង | ជាចៅក្រម |
| ៤-លោក គុប ឈុនហេង | ជាព្រះរាជអាជ្ញារង |

ឆ-តុលាការ-អយ្យការក្រុងព្រះសីហនុ

| | |
|---|---|
| ១-លោក ម្លូង សំណាង | ជាចៅក្រម |

២-លោក **តាំង ស៊ុនឡាយ** ជាចៅក្រម

៣-លោក **ឈាង ស្រេង** ជាព្រះរាជអាជ្ញារង

ជ-តុលាការ-អយ្យការខេត្តកំពង់ឆ្នាំង

១-លោក **ទេង ហ៊ត់** ជាចៅក្រម

២-លោក **ហេង លុយ** ជាព្រះរាជអាជ្ញារង

ឈ-តុលាការ-អយ្យការខេត្តបាត់ដំបង

១-លោក **ឌុច សុខសារិន** ជាចៅក្រម

២-លោក **អ៊ុំ ចាន់ថុល** ជាចៅក្រម

៣-លោក **គី ឫទ្ធី** ជាចៅក្រម

៤-លោក **ផាន់ វណ្ណរ័ត្ន** ជាចៅក្រម

៥-លោក **គួយ ភាន់យ៉ា** ជាព្រះរាជអាជ្ញារង

៦-លោក **អ៊ុយ សំភារ** ជាព្រះរាជអាជ្ញារង

ញ-តុលាការ-អយ្យការខេត្តសៀមរាប

១-លោក **ខួន ណារ៉ា** ជាចៅក្រម

២-លោក **ប៊ុល សំអឿន** ជាចៅក្រម

៣-លោក **សួស ឡា** ជាចៅក្រម

៤-លោក **គួច សុភក្តី** ជាព្រះរាជអាជ្ញារង

៥-លោក **នួន សាន** ជាព្រះរាជអាជ្ញារង

ដ-តុលាការខេត្តបន្ទាយមានជ័យ

១-លោក **អ៊ិក ផល្លា** ជាចៅក្រម

ឋ-តុលាការខេត្តកំពង់ធំ

១-លោក **ជុំ ស** ជាចៅក្រម

ឌ-តុលាការ-អយ្យការខេត្តកំពង់ចាម

១-លោក **ផួង វណ្ណា** ជាចៅក្រម

២-លោក **ចាយ ចំន្ទតារាវណ្ណ** ជាចៅក្រម

៣-កញ្ញា គីម លុយ ជាចៅក្រម

៤-លោក ជុំ សែនសុខា ជាព្រះរាជអាជ្ញារង

ឈ-តុលាការ-អយ្យការខេត្តព្រៃវែង

១-លោក អ៊ុក សុខវណ្ណារិទ្ធ ជាចៅក្រម

២-លោក សែត ទិសិដ្ឋមុនី ជាចៅក្រម

៣-លោក ចំនួ តារាស្រី ជាព្រះរាជអាជ្ញារង

ញ-តុលាការ-អយ្យការខេត្តស្វាយរៀង

១-លោក លី លីមម៉េង ជាចៅក្រម

២-លោក ទ្រី សុភ័ត ជាចៅក្រម

៣-លោក កែវ សុធា ជាព្រះរាជអាជ្ញារង

ត-អយ្យការខេត្តក្រចេះ

១-លោក គង់ សិសារ៉េត ជាព្រះរាជអាជ្ញារង

ថ-តុលាការខេត្តស្ទឹងត្រែង

១-លោក គង់ ចំនួខេមរិទ្ធ ជាចៅក្រម

ទ-តុលាការខេត្តកោះកុង

១-លោក លាង សំណាត់ ជាចៅក្រម

លោក លោកស្រី និង កញ្ញា ដែលមានឈ្មោះដូចខាងលើនេះ ត្រូវបំពេញកម្មសិក្សារយៈពេល ១ ឆ្នាំ ចាប់ពីថ្ងៃតែងតាំងនេះតទៅ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

នស/រកត/១២០៥/៥៧៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាយ ឌាន់

នស/រកត/១២០៥/៥៣៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំង ប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសបទ

**មាត្រា១ .-** ត្រូវបានសំរួលភារកិច្ច ឯកឧត្តម **ស៊ិន សារុន** ដោយបញ្ចប់សមាជិកភាព ជាសមាជិកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

**មាត្រា២ .-** តែងតាំងឯកឧត្តម **ភាន់ ម៉ុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ជំនួសឯកឧត្តម **ស៊ិន សារុន** ។

**មាត្រា៣ .-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣៦៧-០៥១២.៥៧៥*

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ១២ ឆ្នាំ ២០០៥

លេខៈ ០៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម ឈួន សុធី ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដែលជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៥១២.៥៧៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ០៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាអ៊ី តាន់**

នស/រកត/១២០៥/៥៣៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា អគ្គខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម សាត សាមី ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤.០៥១២.៥៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ០១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារ៉ាឌី តាន់**

CPL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០០ រៀល គំរូថ្មី

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**មាត្រា១** : អនុញ្ញាតឱ្យចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ប្រភេទ ១០០០ រៀល គំរូថ្មី ទន្ទឹមនឹងបណ្តាប្រភេទប្រាក់ដែលមានចេញផ្សាយរួចមកហើយ ។

**មាត្រា២** : ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាស ដើម្បីផ្សព្វផ្សាយពីលក្ខណៈសំគាល់នៃក្រដាសប្រាក់ប្រភេទ ១០០០ រៀល គំរូថ្មីនេះ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ..០៣...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្តូរឈ្មោះមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា១ :** ត្រូវបានប្តូរឈ្មោះមុខតំណែងក្នុងរចនាសម្ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិជូនមន្ត្រីរាជការដូចមានរាយនាមខាងក្រោម :

១- លោក **សេង សឿន** ពីនាយករងវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ

២- លោកស្រី **ហង់ លីណា** ពីនាយករងវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ

៣- លោក **ខៀវ សាវី** ពីនាយករងវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ

៤- លោក **ហាស់ ប៊ុនថ្លង** ពីនាយករងវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:....០៤...អនក្រ...បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
បក
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាងអគារសិក្សា នៅអនុវិទ្យាល័យបាទៀវ ក្នុងស្រុកឈូក ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-ឧកញ៉ា **អ៊ាំង ធ្វី** ថវិកា ចំនួន ១០.០០០ USD
២-ឧកញ៉ា **អ៊ុំ នាយ** ថវិកា ចំនួន ១០.០០០ USD
៣-លោកវរសេនីយ៍ត្រី **នីវ សាវុធ** ថវិកា ចំនួន ១០.០០០ USD
៤-លោក THANG CHIV HOR ប្រធានក្រុមហ៊ុន យ៉ុងវ៉ា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញៈថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:.....០៥...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
៚
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយកសាងសមិទ្ធផលផ្សេងៗ នៅយោធភូមិភាគ ទី៤ និង ឃុំបាទ្បេវ ស្រុកឈូក ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ង្វៀង ហ្វាង ស៊ីន** (NGUYEN HOANG SON) ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ ខេត្តប៊ិន យឿង

២-ឯកឧត្តម **ង្វៀង ទន់ មិញ** (NGUYEN TUAN MINH) ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ ខេត្តវង់ តាវ

៣-ឯកឧត្តម **ហ៊ុង ជី ថាំង** (HUYNH CHI THANG) អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ ខេត្តដុង ណាយ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១** : ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី ស៊ុំ ច័ន្ទទុន្នី អនុមន្ត្រីថ្នាក់លេខ ៦ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ អោយបំពេញមុខងារជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាការឡើងឋានន្តរស័ក្តិ និងថ្នាក់ទៅតាមគោលការណ៍ដូចមានចែងក្នុងលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល:**
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

៚៙៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** ផ្លាស់លោក សុ សីឡា បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា ១ :** ផ្លាស់លោក **ភាន់ ផារិទ្ធ** បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

៙៙៙

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ :** ផ្ដាស់លោក សំ ថន បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល:**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ផ្លាស់លោកស្រី **យស់ ម៉ារ៉ាណា** បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ០១ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ២
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រអ លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **អាំង អេងធីមតេង** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី និងជាជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **អ៊ុង ឃាំង** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **ចាន់ រតនា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **ម៉ៅ វ៉ាន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានផែនការ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

*

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ចំនួន ០៧គ្រឿង ជូនកងទ័ពជើងទឹកប្រជាជនវៀតណាមចំនួន ០៧ រូប ដែលមានស្នាដៃក្នុងការធ្វើសហប្រតិបត្តិការ ជួយឧបត្ថម្ភដល់ កងទ័ពជើងទឹក នៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

- ឧត្តមនាវីទោ **ង្វៀន វ៉ាន់ហៀន** ( Nguyen Van Hien ) មេបញ្ជាការ កងទ័ពជើងទឹក

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា :**

១-ឧត្តមនាវីត្រី **ត្រឹន ថាញ់ហ្វៀង** ( Tran Thanh Huyen ) ប្រធានស្នងការនយោបាយ កងទ័ពជើងទឹក

២-ឧត្តមនាវីត្រី **ផាម ឌឹកលិញ** ( Pham Duc Linh ) ប្រធានស្នងការប៉ូលីសព្រំដែន កងទ័ពជើងទឹក

**គ-មេដាយសហមេត្រី ថ្នាក់អស្សឫទ្ធិ :**

១-វរនាវីឯក **ផាម វ៉ាន់ហ្វាញ** ( Pham Van Hoanh ) អនុប្រធានសេនាធិការ កងទ័ពជើងទឹក

២-វរនាវីឯក កាវ ហ្វាប៊ិញ ( Cao Hoa Binh ) អនុប្រធានស្ទួងការបច្ចេកទេស កងទ័ពជើងទឹក

៣-វរនាវីឯក ដូន វ៉ាន់ស៊ើ ( Doan Van So ) មេបញ្ជាការតំបន់ទី៥ កងទ័ពជើងទឹក

៤-វរនាវីឯក ង្វៀង ង៉ុកវិញ ( Nguyen Ngoc Vinh ) ប្រធានមន្ទីរទាក់ទងអន្តរជាតិ កងទ័ពជើងទឹក

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ.ទាជ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តន៍ចុះបញ្ជីពន្ធដាររបស់សហគ្រាសវិនិយោគ

អនុលោមតាមខ្លឹមសារអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ដើម្បីសំរួលដល់ការចុះបញ្ជីពន្ធដាររបស់សហគ្រាសវិនិយោគ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំដូចខាងក្រោម:

១- អ្នកស្នើសុំវិនិយោគ ត្រូវបានបង់ប្រាក់ថ្លៃចុះបញ្ជី ចំនួន៧,០០០,០០០រៀល ចូលថវិកាជាតិតាមរយ: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលក្នុងនោះរួមមានផងដែរ នូវពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រ៍ ។

២- ក្នុងកិច្ចដំណើរការចុះបញ្ជីនៅពន្ធដារ អង្គភាពពន្ធដារមិនត្រូវទាមទារឱ្យបង់ប្រាក់ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រ៍ទៀតឡើយ ។ អ្នកវិនិយោគត្រូវបំពេញបែបបទលិខិតស្នាមនៃការចុះបញ្ជីពន្ធដារ តាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ហើយរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជាបន្ទាន់ជូនទៅអ្នកវិនិយោគនូវប័ណ្ណប៉ាតង់ និង វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ទំរង់ អតប ១០៤) នៅក្រោយពេលសង្កេតឃើញថាឯកសារនៃការចុះបញ្ជីមានលក្ខណៈគ្រប់គ្រាន់ហើយនោះ ។

៣- ចំណូលពីពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា និង ពន្ធតែមប្រ៍ ដែលបានពីការចុះបញ្ជីរបស់អ្នកវិនិយោគ នាយកដ្ឋានពន្ធដារមិនមានចុះកិច្ចបញ្ជីការរបស់ខ្លួនឡើយ ។ នៅលើលិខិតប្រកាសពន្ធរបស់អ្នកវិនិយោគ រដ្ឋបាលសារពើពន្ធ ត្រូវកត់ត្រាយោងលិខិតលេខ ចុះថ្ងៃខែ នៃលិខិតរបស់ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលបានទទួលប្រាក់ថ្លៃចុះបញ្ជី ចំនួន ៧,០០០,០០០រៀល នោះ ដោយមិនចាំបាច់ចេញបង្កាន់ដៃពន្ធជូននោះឡើយ ។

ទទួលបានសារាចរណែនាំនេះ សូមលោកប្រធាននាយកដ្ឋានពន្ធដារ ចាត់ចែងអនុវត្តអោយទទួលបានទូវប្រសិទ្ធភ ខ្ពស់ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- សាខាពន្ធដារខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦

លេខ ០០១ សហវ.

# សេចក្តីជូនដំណឹង
## ស្តីពីកាតព្វកិច្ចអាករលើតម្លៃបន្ថែម (VAT)

ដើម្បីជាការក្រើនរំលឹកអំពីកាតព្វកិច្ចប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់សហគ្រាស ក្រុមហ៊ុនទាំងអស់ដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) ឱ្យបានជ្រាបថា អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាស ក្រុមហ៊ុន ដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែម គឺជាបុគ្គលដែលទទួលខុសត្រូវចំពោះមុខច្បាប់លើការប្រមូលប្រាក់អាករលើតម្លៃបន្ថែម (VAT) ពីអតិថិជនដែលជាអ្នកប្រើប្រាស់ និងត្រូវបង់ប្រាក់អាករដែលជាប្រាក់របស់រដ្ឋទាំងនោះជូនរដ្ឋបាលសារពើពន្ធ ។ សហគ្រាស ក្រុមហ៊ុន ទាំងនោះត្រូវកំណត់និងប្រមូលប្រាក់អាករតាមអត្រា ១០ ភាគរយ នៃទឹកប្រាក់ដែលត្រូវគិតយកពីអតិថិជន ។ ក្នុងករណីដែលមិនបានបង្ហាញទឹកប្រាក់អាករលើតម្លៃបន្ថែម (VAT) នៅលើវិក្កយបត្រ ទឹកប្រាក់សរុបនៅលើវិក្កយបត្រនោះត្រូវបានចាត់ទុកថាមានរួមបញ្ចូលទាំងអាករលើតម្លៃបន្ថែម ។ បំណុលអាករលើតម្លៃបន្ថែម (VAT) មានចំនួនស្មើនឹងទឹកប្រាក់សរុបលើវិក្កយបត្រចែកនឹង ១១ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមថ្លែងសសើរចំពោះសហគ្រាស ក្រុមហ៊ុនមួយចំនួន ដែលបានគោរពប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដោយបានប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋ ជូនរដ្ឋបាលសារពើពន្ធបានត្រឹមត្រូវ ទៀងទាត់ និងទាន់ពេលវេលា ។

ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យឃើញថាមាន សហគ្រាស ក្រុមហ៊ុន មួយចំនួនមិនទាន់គោរពបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (VAT) បានត្រឹមត្រូវនៅឡើយ ។ សហគ្រាស ក្រុមហ៊ុន ខ្លះបានប្រមូលអាករលើតម្លៃបន្ថែម (VAT) ពីអតិថិជនហើយ ប៉ុន្តែមិនបានយកប្រាក់អាករមកបង់ជូនរដ្ឋបាលសារពើពន្ធឡើយ ដោយកិបកេងយកប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋទុកជាផលប្រយោជន៍របស់ខ្លួន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ឱ្យសហគ្រាស ក្រុមហ៊ុនដែលអនុវត្តមិនបានត្រឹមត្រូវដូចបានជម្រាបជូនខាងលើ ប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែយ៉ាងយឺតបំផុតនៅថ្ងៃទី២០ នៃខែ បន្ទាប់ពីខែដែលទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ ។ ដោយឡែកចំពោះប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលសហគ្រាស ក្រុមហ៊ុនមួយចំនួនបានប្រមូលពីអតិថិជនរួចហើយ ប៉ុន្តែនៅមិនទាន់បានបង់ជូនរដ្ឋទេនោះ ត្រូវរួសរាន់បង់ប្រាក់អាករលើតម្លៃបន្ថែមដែលជាប្រាក់របស់រដ្ឋនោះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅដំណាច់ខែមករា ឆ្នាំ២០០៦ នេះជាកំហិត ។ បើហួសពីរយៈពេលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងប្រើអំណាចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងផ្នែកទី៦នៃច្បាប់ស្តីពីសារពើពន្ធមានជាអាទិ៍ ការបញ្ឈប់សកម្មភាពអាជីវកម្ម ការឃាត់ទុកគណនីធនាគារ និងការទុកជាមោឃៈនូវលិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណនានា ឬក៏អាចនឹងឈានទៅដល់ការប្តឹងចោទប្រកាន់ទៅតុលាការស្តីពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក លោកស្រី ប្រធានសហគ្រាស ក្រុមហ៊ុន ដែលអនុវត្តមិនបានត្រឹមត្រូវដូចបានជម្រាបជូនខាងលើ នឹងបំពេញកាតព្វកិច្ចប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម(VAT) បានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា តាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន មិនខាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...០០២.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកិត្តិយសសូមជម្រាបដល់ម្ចាស់សហគ្រាសឯកជន ឯកជនចំរុះរដ្ឋ រដ្ឋ ព្រមទាំងអង្គភាពសេដ្ឋកិច្ច ដែលបាននិងកំពុងដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមមេត្តាជ្រាបថា ÷

ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨/០៧/២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យ និងស្តង់ដារសវនកម្មកម្ពុជា លេខ ៧៩៨ និង ៧៩៩ សហវ ចុះថ្ងៃទី ១៦/ ១០/២០០៣ ចាប់ពីថ្ងៃ ទី ០១ ខែ មករា ឆ្នាំ ២០០៥ មក ។

រាល់សហគ្រាសត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ដោយកាន់កិច្ចបញ្ជីការគណនេយ្យ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុទៅតាមគោលការណ៍ស្តង់ដារគណនេយ្យកម្ពុជា ដែលឈរលើមូលដ្ឋានស្តង់ដារគណនេយ្យអន្តរជាតិ ។ ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ និងទៀងទាត់ នឹងផ្តល់គុណប្រយោជន៍យ៉ាងច្រើនដល់សហគ្រិន ម្ចាស់ក្រុមហ៊ុន ព្រោះថា បញ្ជីគណនេយ្យជាការវាស់វែងនូវប្រសិទ្ធភាព សមត្ថភាព គុណភាពនៃសេវា និងជាការបញ្ជាក់អំពីសមិទ្ធិផលរបស់ក្រុមហ៊ុន ។

តាមការសិក្សា និងការអង្កេតជាក់ស្តែងរបស់ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការសហប្រជាជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននៅលើសកលលោកបានបង្ហាញឱ្យឃើញថា ការអនុវត្តនូវគោលការណ៍ស្តង់ដារគណនេយ្យបានជួយម្ចាស់សហគ្រាសពង្រឹងការគ្រប់គ្រងអាជីវកម្មរបស់ខ្លួនកាន់តែមានភាពប្រសើរឡើង ពីព្រោះមានបញ្ជី និងសក្ខីប័ត្រ ឬរបាយការណ៍ហិរញ្ញវត្ថុដែលកើតឡើងពីការប្រមូលផ្តុំគណនីនៅក្នុងដៃ អាចជួយដល់ការតាមដានប្រតិបត្តិការបានល្អ និងមានប្រសិទ្ធភាពខ្ពស់ ។

ផ្អែកលើភាពត្រឹមត្រូវនិងគួរឱ្យទុកចិត្តបាននៃកិច្ចបញ្ជីការគណនេយ្យ ក្រុមហ៊ុនអាចប្រើឯកសារ ដែលមានមូលដ្ឋានព័ត៌មានដ៏រឹងមាំទាំងនេះសំរាប់ខ្ចីទុនពីធនាគារ ឬទីផ្សារទុននៅពេលក្រុមហ៊ុនជួបកង្វះខាតហិរញ្ញវត្ថុ ។

ជាមួយគ្នានេះ រដ្ឋាភិបាលកំពុងតែរៀបចំច្បាប់ដើម្បីបង្កើតទីផ្សារទុនក្នុងពេលឆាប់ៗនេះ ។ ដូច្នេះសហគ្រាសដែលមានមូលដ្ឋាននៃកិច្ចបញ្ជីការគណនេយ្យត្រឹមត្រូវនិងជឿទុកចិត្តបានហើយអាចស្នើសុំទៅអាជ្ញាធរគ្រប់គ្រងផ្សារទុន ដើម្បីដាក់ឈ្មោះសហគ្រាសរបស់ខ្លួននៅក្នុងបញ្ជីផ្សារទុន ដែលជាប្រភពគៀងគរមូលនិធិដ៏មានប្រសិទ្ធភាពបំផុតក្នុងការវិនិយោគ ។

**ក្រុមប្រឹក្សាជាតិគណនេយ្យ** ដែលស្ថិតក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រងចាំទទួលនូវរាល់សំណូមពរ ឬ ចម្ងល់ទាំងឡាយរបស់ម្ចាស់ក្រុមហ៊ុន និងសហគ្រិនទាំងអស់ដែលទាក់ទងនឹងការអនុវត្តស្តង់ដារគណនេយ្យ និងសវនកម្មកម្ពុជា សម្រាប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ៕

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation Religion King**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 002 MEF/..............

Phnom Penh, 06 January 2006

# NOTICE

The Ministry of Economy and Finance has the honor to inform the owners and heads of private, private-state and state owned enterprises, and economic entities operating in the Kingdom of Cambodia that pursuant to Royal Kram No. NS/RKM/0702/011 promulgating the law on corporate accounts, their audits, and accountancy profession on 08 July 2002, the Ministry of Economy and Finance had issued Prakas No. 798 & 799 MEF on 16 October 2003 to implement the Cambodian Accounting Standards (CAS) and Cambodian Standards on Auditing (CSA) ever since 01 January 2005.

All enterprises must comply with the Prakas by maintaining account records and making financial reporting according to the principles of CASs which are based on International Accounting Standards (IAS). By keeping account records properly and consistently, it will bring significant benefit to the entrepreneurs and owners of enterprises as accounting records is the measurement of effectiveness, competency, and quality of performance, and reflection of achievements of the entities.

According to clear studies and investigations by the World Bank, ADB, IMF, and the UN in many developing countries in the world, it shows that the implementation of the principles of accounting standards helps enterprises' owners in strengthening the controlling of their businesses better because having the records and evidences or financial reporting accumulated by various accounts in hand could help tracking their operations effectively and efficiently.

On the basis of the integrity and reliability of these accounting records, companies can utilize these solid information-based documents to borrow capitals from the banks and capital markets when companies are short of financial resources.

In the meantime, the government is preparing a law to establish the stock market in the near future. Therefore, companies with fair and reliable accounting records can request the securities authority to list their companies on the stock exchange where it is the best source to mobilize the fund for the capital investment.

The **National Accounting Council**, under the tutelage of the Ministry of Economy and Finance, is anticipating to receiving from owners of enterprises and entrepreneurs all propositions or any doubts related to the application of CAS and CSA for all enterprises in the Kingdom of Cambodia.

Keat Chhon
Sr. Minister,
Minister of Economy and Finance

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ០០៤ ឧរក.កន(ប្រ)

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៩៦/០៥ គ.វ.ក ចុះថ្ងៃទី០៣.១១.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ភីស គ្លរី (ខេមបូឌា) មេនូហ្វេកឈ័ររីង ចុះថ្ងៃទី០៩.០៩.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ភីស គ្លរី (ខេមបូឌា) មេនូហ្វេកឈ័ររីង (PEACE GLORY (CAMBODIA) MANUFACTURING CO., LTD.) តំណាងដោយ លោកស្រី CHUN SUSAN MUN KWAN សញ្ជាតិកាណាដា អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ BC155395 ចុះថ្ងៃទី២០.១២.២០០០ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ភីស គ្លរី (ខេមបូឌា) មេនូហ្វេកឈ័ររីង (PEACE GLORY (CAMBODIA) MANUFACTURING )" មានទីតាំងស្ថិតនៅ ភូមិទូលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

<u>ប្រការ២</u>: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៣</u>: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤</u>: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥</u>: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦</u>: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧</u>: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨</u>: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩</u>: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ភីស គួរី (ខេមបូឌា) មេនូហ្វេកឈ័ររីង ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

<u>ប្រការ១០</u>: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

<u>ចម្លងជូន</u> :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៧ ពណ.នគក

ភ្នំពេញថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៦

## សេចក្តីសម្រេច រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រស្មី សួគ៌ ហ្វាម៉ា**
**RASMEY SUOR PHARMA Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8233/05P ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ហោ ស្រ៊ុន** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ហោ ឈុន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ២២៦៧ ឌ ផ្លូវសាលាអន្តរជាតិ ន័រប្រិត សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួលដុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកព័ត៌មានដឹងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
